# សម័យប្រជុំល្ងាចថ្ងៃអាទិត្យ

ថ្ងៃទី 6 ខែ មេសា ឆ្នាំ 2008

## "កិច្ចការយើងនោះគ្មានថ្ងៃបញ្ចប់ឡើយ ហើយ...ព្រះបន្ទូលរបស់យើង... ពុំដែលឈប់ឈរឡើយ"

អែលឌើរ ជែហ្វ្រី អរ៍ ហាឡិន
នៃក្រុមសាវកនៃពួក 12 នាក់

*យើងសូមអញ្ជើញមនុស្សទាំងអស់ឱ្យសួរដោយស្មោះត្រង់អំពីអ្វីដែលព្រះបានមានបន្ទូលចាប់តាំងពីជំនាន់ព្រះគម្ពីរប៊ីប ហើយកំពុងតែមានព្រះបន្ទូលនៅក្នុងពេលឥឡូវនេះ ។*

ប្រធានម៉នសុន តើខ្ញុំអាចប្រកាសមួយភ្លែតអំពីឯកសិទ្ធិផ្ទាល់ខ្លួនបានឬទេ?

នៅក្នុងនាមជាបងប្អូនប្រុសដំបូងនៃបងប្អូនប្រុស ដែលបានអញ្ជើញឱ្យនិយាយតាមសារលិខិតតែមួយរបស់លោកចំពោះសាសនាចក្រនៅព្រឹកនេះ ខ្ញុំសូមនិយាយអំពីអ្វីមួយ ដែលតំណាងឱ្យបងប្អូនប្រុសរបស់អ្នក នៃអ្នកមានសិទ្ធិអំណាចទូទៅ និងជាតំណាងឱ្យសាសនាចក្រទាំងអស់ ។

នៅក្នុងឯកសិទ្ធិជាច្រើន ដែលយើងបានមានសន្និសីទដ៏ជាប្រវត្តិសាស្ត្រនេះ រួមមានទាំងការចូលរួមនៅក្នុងការប្រជុំដ៏ឧឡារិកមួយ ដែលយើងអាចក្រោកឈរ និងគាំទ្រដល់លោកក្នុងនាមជាព្យាការី អ្នកមើលឆុត និងអ្នកទទួលវិវរណៈ ខ្ញុំមិនអាចទប់អារម្មណ៍នៃឯកសិទ្ធិដ៏សំខាន់បំផុតដែលយើងបានមានទេ ទាំងអស់នេះបានធ្វើជាសាក្សីផ្ទាល់ក្នុងការដាក់នូវភាពពិសិដ្ឋ ភាពជាព្យាការីមកលើស្មារបស់លោក ដែលស្ទើរតែធ្វើឡើងដោយព្រះហស្តរបស់ពួកទេវតាដោយផ្ទាល់ ។ អ្នកទាំងឡាយដែលបានចូលរួមនៅក្នុងការប្រជុំបព្វជិតភាពទូទៅនៅយប់នេះ ហើយអ្នកទាំងឡាយដែលបានមានវត្តមាននៅក្នុងការចាក់ផ្សាយទូទាំងពិភពលោក នៃសម័យប្រជុំព្រឹកនេះ បានធ្វើជាសាក្សីជាក់នឹងភ្នែកចំពោះព្រឹត្តការណ៍នេះ ។ អស់អ្នកដែលចូលរួម ខ្ញុំសូមបង្ហាញនូវការដឹងគុណរបស់យើង ចំពោះពេលនោះ ។ ខ្ញុំសូមនិយាយដោយក្ដីស្រឡាញ់ទៅដល់ប្រធានម៉នសុន ហើយជាពិសេសចំពោះព្រះវរបិតា ដែលគង់នៅស្ថានសួគ៌របស់យើង សំរាប់ឱកាសដ៏មហិមានេះ ដែលបានធ្វើជា "ស្មរបន្ទាល់ដែលបានឃើញឫទ្ធានុភាពរបស់ទ្រង់ជាក់នឹងភ្នែក" (ពេត្រុសទី 2 1:16) ដែលបាននិយាយដោយសាវកពេត្រុសក្នុងគ្រាមួយ ។

នៅក្នុងសន្និសីទទូទៅខែ តុលា ឆ្នាំមុន ខ្ញុំបាននិយាយថាមានគោលការណ៍ពីរដែលធ្វើឱ្យសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយត្រូវបានចោទប្រកាន់ដោយភាន់ច្រឡំថាមិនមែនជាពួកគ្រីស្ទាន ។ នៅពេលនោះខ្ញុំបានថ្លែងសុន្ទរកថាអំពីគោលលទ្ធិមួយនៃគោលលទ្ធិដែលចោទជាបញ្ហា---គឺទស្សនៈនៃព្រះគម្ពីរជាមូលដ្ឋានរបស់យើងអំពីក្រុមព្រះ ។ នៅថ្ងៃនេះ ខ្ញុំសូមថ្លែងនូវសុន្ទរកថានូវគោលលទ្ធិដ៏សំខាន់មួយទៀត ដែលបង្ហាញនូវបុគ្គលិកលក្ខណៈនៃសេចក្ដីជំនឿរបស់យើង ដូចជាគឺការអះអាងដ៏មុតមាំដែលថាព្រះបន្តមានព្រះបន្ទូល ហើយបើកសម្ដែងសេចក្ដីពិតរបស់ទ្រង់ វិវរណៈទាំងឡាយដែលអនុញ្ញាតឱ្យប្រមូលគម្ពីរនានា ហើយបញ្ចូលជាព្រះគម្ពីរ ប៉ុន្តែវានឹងបណ្ដាលឱ្យមនុស្សមួយចំនួនមានចម្ងល់ ។

ពួកគ្រីស្ទានភាគច្រើន ពីព្រោះតែសេចក្ដីស្រឡាញ់ដ៏មុតមាំរបស់ពួកគេចំពោះព្រះគម្ពីរប៊ីប បានប្រកាសថា គ្មាន

ព្រះគម្ពីរណាដែលមានសិទ្ធិអំណាចជាងព្រះគម្ពីរប៊ីបទៀតទេ។ តាមរយៈការអានទូវបទដ្ឋាននៃវិវរណៈចុងបញ្ចប់មិត្តភក្តិរបស់យើងដែលមានជំនឿខុសពីយើង បដិសេធនូវការបង្ហាញដ៏ទេវភាពដែលយើងមាននៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ដែលមានតម្លៃ---គឺព្រះគម្ពីរមរមន ព្រះគម្ពីរគោលលទ្ធិ និងសេចក្តីសញ្ញា ព្រះគម្ពីរមុក្តាដ៏មានតម្លៃមហិមា និងការដឹកនាំដែលកំពុងកើតមានឡើង ដែលបានទទួលដោយព្យាការី និងសាវកដែលបានតែងតាំងរបស់ព្រះ។ ខណៈដែលគ្មានចេតនាអាក្រក់ចំពោះជនទាំងឡាយណា ដែលធ្វើបែបនោះ យ៉ាងណាក៏ដោយយើងគោរពប៉ុន្តែសូមបដិសេធទាំងស្រុងនូវបុគ្គលិលក្ខណៈដែលថាគ្មានព្រះគម្ពីរបែបនោះ នៃពួកគ្រីស្ទានពិតប្រាកដ។1

ក្នុងការឈ្លោះប្រកែកមួយ ជាញឹកញាប់ត្រូវបានធ្វើឡើងនៅក្នុងការការពារដល់បទដ្ឋានចុងក្រោយនៅក្នុងសារលិខិត នៃព្រះគម្ពីរសញ្ញាថ្មី ដែលបានកត់ត្រានៅក្នុងវិវរណៈ 22:18។ "ខ្ញុំធ្វើបន្ទាល់ដល់អស់អ្នកណាដែលឮពាក្យ... ក្នុងគម្ពីរ នេះថាបើអ្នកណាបញ្ចូលអ្វីក្នុងសេចក្តីទាំងនេះ នោះព្រះទ្រង់នឹងបន្ថែមអស់ទាំងសេចក្តីវេទនា ដែលកត់ទុកក្នុងព្រះគម្ពីរនេះដល់អ្នកនោះផង"។ ទោះជាយ៉ាងណាក៏ដោយ ឥឡូវនេះក៏មាននូវការព្រមព្រៀងដោយរំជួលចិត្តនៅក្នុងចំណោមពួកអ្នកប្រាជ្ញខាងព្រះគម្ពីរប៊ីបជាក់ស្តែងផងដែរថា ខគម្ពីរនេះអនុវត្តចំពោះតែព្យាការីនៃព្រះគម្ពីរវិវរណៈ ប៉ុណ្ណោះ *មិនមែន* ព្រះគម្ពីរប៊ីបទាំងមូលនោះទេ។ ពួកអ្នកប្រាជ្ញទាំងនោះនៃសម័យរបស់យើងបានទទួលស្គាល់ ព្រះគម្ពីរសញ្ញាថ្មីមួយចំនួនថាជា "ព្រះគម្ពីរ" ដែលបានសរសេរស្ទើរតែត្រឹមត្រូវបំផុត *បន្ទាប់ពី* ការទទួលវិវរណៈរបស់ យ៉ូហាននៅលើកោះឈ្មោះ ប៉ាត់ម៉ុស។ រួមទាំងនៅក្នុងផ្នែកនេះគឺយ៉ាងហោចណាស់ព្រះគម្ពីរពេត្រុសទី 1 និង 2 គម្ពីរពួកចៅហ្វាយ និងសំបុត្ររបស់យ៉ូហាន និងប្រហែលជាដំណឹងល្អទាំងមូលរបស់យ៉ូហានដោយផ្ទាល់។1 ប្រហែលជាមានច្រើនជាងនេះទៀត។

ប៉ុន្តែមានចម្លើយដ៏សាមញ្ញជាង ដូចជា ហេតុអ្វីសារលិខិតនោះនៅក្នុងព្រះគម្ពីរចុងក្រោយនៃព្រះគម្ពីរសញ្ញាថ្មីបច្ចុប្បន្ន បើមិនអាចអនុវត្តនៅក្នុងព្រះគម្ពីរប៊ីបទាំងមូល។ នោះគឺពីព្រោះព្រះគម្ពីរប៊ីបទាំងមូល ដូចដែលយើងបានស្គាល់---វាជាការប្រមូលផ្តុំនៃអត្ថបទមួយ ដែលបានចងក្រងនៅក្នុងព្រះគម្ពីរតែមួយក្បាល---ដែលមិនមាននៅពេលខនោះ ត្រូវបានសរសេរទេ។ អស់ជាច្រើនសតវត្សរ៍ បន្ទាប់ពីយ៉ូហានចេញនូវការសរសេររបស់គាត់ សៀវភៅគម្ពីរនីមួយៗនៃព្រះគម្ពីរសញ្ញាថ្មីគឺបានផ្សាយតែឯង ឬប្រហែលជាក្នុងការចងក្រងជាមួយនឹងអត្ថបទដទៃទៀត ប៉ុន្តែស្ទើរតែ *មិនដែល* ជាការចងក្រងពេញលេញនោះទេ។ ការប្រមូលផ្តុំទាំងអស់ចំនួន 5,366 ដែលត្រូវបានស្គាល់ថាជាការសរសេរ ជាព្រះគម្ពីរសញ្ញាថ្មីជាភាសាក្រិកមានតែ 35 គម្ពីរមាននៅក្នុងព្រះគម្ពីរសញ្ញាថ្មីទាំងមូលដូចដែលបានស្គាល់ឥឡូវនេះ ហើយគម្ពីរទាំង 34 នោះត្រូវបានចងក្រងក្រោយពី 1000 គ. ស.។2

ភាពពិតនៃបញ្ហានេះគឺជាក់ស្តែងរាល់ព្យាការីទាំងអស់នៃព្រះគម្ពីរសញ្ញាចាស់ *និង* សញ្ញាថ្មីបានបន្ថែមព្រះគម្ពីរចំពោះអ្វីដែលបានទទួលដោយពួកអ្នកនៅពីមុនគាត់។ បើពាក្យសំដីនៃម៉ូសេនៃព្រះគម្ពីរសញ្ញាចាស់គ្រប់គ្រាន់ហើយ ដូចដែលមានមនុស្សមួយចំនួនយល់ខុស។ 3 ឧទាហរណ៍ បន្ទាប់មកតើហេតុអ្វីក៏ត្រូវការមានពាក្យព្យាករណ៍របស់អេសាយ ឬយេរេមា ដែលនៅបន្ទាប់ពីអេសាយនោះ? ថែមទាំងអេសេគាល និងដានីយ៉ែល នៃយ៉ូអែល អេម៉ុស និងព្យាការីដទៃទៀតទាំងអស់។ បើវិវរណៈមួយចំពោះព្យាការីម្នាក់នៅក្នុងពេលមួយគ្រប់គ្រាន់សំរាប់គ្រប់ពេល *ទាំងអស់* តើការណ៍ជាច្រើនផ្សេងទៀតធ្វើឡើងត្រឹមត្រូវជាយ៉ាងណាដែរ? អ្វីដែលធ្វើឱ្យការណ៍ទាំងនេះត្រឹមត្រូវ គឺត្រូវបានពន្យល់យ៉ាងច្បាស់ ដោយព្រះយេហូវ៉ាទ្រង់ផ្ទាល់ នៅពេលដែលទ្រង់មានបន្ទូលទៅកាន់ម៉ូសេថាៈ "កិច្ចការយើង នោះគ្មានថ្ងៃបញ្ចប់ឡើយ ហើយ...ព្រះបន្ទូលរបស់យើង... ពុំដែលឈប់ឈរឡើយ"។4

អ្នកប្រាជ្ញប្រូតេស្តង់ម្នាក់បានសិក្សាស្វែងយល់យ៉ាងខ្លាំងអំពីគោលលទ្ធិដែលភាន់ច្រឡំ នៃបទដ្ឋាននៅចុងបញ្ចប់។ គាត់បានសរសេរថា: "តើនៅក្នុងព្រះគម្ពីរប៊ីប ឬរដូវកាលខាងប្រវត្តិសាស្ត្រណាដែលការបំផុសគំនិតពីព្រះត្រូវបានកំណត់ការសរសេរនូវឯកសារដែលព្រះវិហារ ឥឡូវនេះហៅថាព្រះគម្ពីរប៊ីបនោះ?... បើព្រះវិញ្ញាណបានបំផុសតែចំពោះឯកសារដែលបានសរសេរនៅសតវត្សរ៍ដំបូង តើនោះមានន័យថាព្រះវិញ្ញាណដូចគ្នានោះមិនបានមានព្រះបន្ទូលនៅសព្វថ្ងៃនេះនៅក្នុងព្រះវិហារ អំពីបញ្ហាដែលជាកង្វល់ដ៏សំខាន់ទេឬអី?" 5 យើងសូមសួរសំណួរដូចគ្នាទាំងនោះដោយរាបសារ។

វិវរណៈដែលកំពុងបន្តមិនធ្វើឱ្យចុះថយ ឬបង្ខូចដល់វិវរណៈដែលមានរួចហើយនោះទេ។ ព្រះគម្ពីរសញ្ញាចាស់មិនបានបាត់បង់តម្លៃនៅក្នុងកេរ្តិ៍តំណែលរបស់យើងទេ នៅពេលយើងត្រូវបានណែនាំឱ្យស្គាល់ព្រះគម្ពីរសញ្ញាថ្មី ហើយព្រះគម្ពីរសញ្ញាថ្មីគ្រាន់តែជាការបន្ថែមនៅពេលយើងអានព្រះគម្ពីរមរមនដែលជា: សក្ខីបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទប៉ុណ្ណោះ។ ក្នុងការពិចារណានូវព្រះគម្ពីរបន្ថែមដែលបានទទួលស្គាល់ដោយពួកបរិសុទ្ធថ្ងៃចុងក្រោយ យើងអាចសួរថា: ពួកគ្រីស្ទានដែលរស់នៅជាច្រើនទសវត្សរ៍មកហើយមានតែដំណឹងល្អនៃម៉ាកុសនៅយុគដំបូង (ដែលជាទូទៅចាត់ទុកថា ដំណឹងល្អនៃសញ្ញាថ្មីដំបូងត្រូវសរសេរ)--- តើពួកគេអាក់អន់ចិត្តក្នុងការទទួលដំណឹងរឿងពីស្តារបន្ថែមដែលបានរៀបចំក្រោយមកដោយម៉ាថាយ និងលូកា ជាការបន្ថែមចំពោះសារលិខិតដ៏ពិសេស និងការសង្កត់ន័យលើវិវរណៈ ដែលក្រោយមកបានផ្តល់ឱ្យដោយយ៉ូហានដែរឬទេ? ប្រាកដណាស់ពួកគេត្រូវតែមានសេចក្តីត្រេកអរ ដែលមានភស្តុតាងធ្វើឱ្យជឿថ្មីទៀត អំពីព្រះគ្រីស្ទដ៏ជាព្រះបន្តផ្តល់ឱ្យ។ ហើយយើងក៏ត្រេកអរផងដែរ។

សូម *កុំ* យល់ខុស។ យើងស្រឡាញ់ ហើយគោរពព្រះគម្ពីរប៊ីប ដូចដែលអែលឌើរ អិម រ័សុល បាឡឺដ បានបង្រៀនយ៉ាងច្បាស់នៅលើវេទិកានេះ ទើបតែមួយឆ្នាំកន្លងទៅនេះ។ 6 ព្រះគម្ពីរប៊ីបគឺជាព្រះបន្ទូលនៃព្រះ។ ព្រះគម្ពីរប៊ីបតែងតែលើកឡើងមុនគេនៅក្នុងបទដ្ឋានរបស់យើងគឺ "បទដ្ឋានព្រះគម្ពីរ" របស់យើង។ ជាការពិតណាស់ វាគឺជាការតែងតាំងដ៏ទេវភាពដែលអានចេញពីខទីប្រាំ នៃជំពូកទីមួយនៃគម្ពីរយ៉ាកុប ដែលបានដឹកនាំលោក យ៉ូសែប ស្ម៊ីធ ទៅកាន់ការនិមិត្តរបស់លោក អំពីព្រះវរបិតា និងព្រះរាជបុត្រា ដើម្បីផ្តល់កំណើតដល់ការស្តារដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនៅសម័យរបស់យើង។ ប៉ុន្តែទោះជាបន្ទាប់ពីពេលនោះក្តី យ៉ូសែប បានដឹងថា ព្រះគម្ពីរប៊ីបតែមួយមិនអាចឆ្លើយចំពោះ *មនុស្សទាំងអស់* អំពីសំណួរសាសនាដែលលោក និងអ្នកដទៃដូចជាលោកមានទេ។ នៅពេលដែលលោកបាននិយាយជាពាក្យសំដីរបស់លោកផ្ទាល់ ពួកអ្នកបង្រៀននៃសហគមរបស់លោកបានមានចិត្តទាស់ប្រកែក---ពេលខ្លះខឹងយ៉ាងខ្លាំង---លើសពីគោលលទ្ធិរបស់ពួកគេ។ លោកបានមានប្រសាសន៍ថា: "អាចារ្យម្នាក់ [បាន] ទាស់នឹងអាចារ្យម្នាក់ទៀត ហើយអ្នកប្រែចិត្តជឿម្នាក់ [បានទាស់] នឹងអ្នកប្រែចិត្តជឿម្នាក់ទៀត... ដោយសារតែការឈ្លោះប្រកែក និងការប្រកួតប្រជែងគ្នាខាងគំនិតជឿ"។ ប្រហែលជារឿងតែមួយប៉ុណ្ណោះ ដែលការទាស់ខាងសាសនាទាំងនេះបានមានជាទូទៅ គឺការសើចចំអកដល់ការជឿលើព្រះគម្ពីរប៊ីប ប៉ុន្តែដូចដែល លោកយ៉ូសែប បានសរសេរថា: "គ្រូបង្រៀនសាសនាពីបក្សពួកផ្សេងៗ គេយល់បទគម្ពីរតែមួយខុសឆ្ងាយពីគ្នាធ្វើយ៉ាង នេះដូចជាបំផ្លាញនូវការទុកចិត្តទាំងអស់ បើចង់បានការដោះស្រាយនូវសំណួរនេះ [ដែលទាក់ទិនថាតើព្រះវិហារណា មួយពិត] ដោយពឹងផ្អែកទៅលើព្រះគម្ពីរប៊ីប"។ 8 ដើម្បីពន្យល់ព្រះគម្ពីរប៊ីបឱ្យបានច្បាស់ ជាញឹកញាប់ត្រូវបានពិពណ៌នានៅពេលនោះថាជា: "ជំនឿជាទូទៅ" គឺគ្មានអ្វីដែលល្អនោះទេ---ផ្ទុយទៅវិញគឺជាឫសគល់នៃទំនាស់ទៅវិញ។

ហេតុដូច្នោះហើយ គោលបំណងដ៏ធំមួយនៃការបន្តវិវរណៈតាមរយៈព្យាការីដែលនៅរស់ គឺដើម្បីប្រកាសដល់ពិភលោក តាមរយៈសាក្សីបន្ថែមថា ព្រះគម្ពីរប៊ីបគឺពិត។ ព្យាការីពីបុរាណបាននិយាយអំពីព្រះគម្ពីរមរមនថា: " *បញ្ជី* នេះ ត្រូវបានសរសេរឡើង" និយាយអំពីព្រះគម្ពីរប៊ីបថា: "ក្នុងគោលបំណងដើម្បីឱ្យអ្នករាល់គ្នាជឿដល់ការណ៍ *នោះ* "។ 8 ដើមឡើយនៅក្នុងវិវរណៈមួយបានទទួលដោយយ៉ូសែប ស្ម៊ីធ ព្រះអម្ចាស់បានមានបន្ទូលថា: "មើលចុះយើងមិននាំ [ព្រះគម្ពីរមរមនមក] ដើម្បីបំផ្លាញ... [ព្រះគម្ពីរប៊ីប] ទេ ប៉ុន្តែដើម្បីកសាងវាឡើង" ។9

ចំនុចមួយទៀតដែលត្រូវតែនិយាយ។ ដោយសារវាច្បាស់លាស់ថា មានពួកគ្រីស្ទានជាយូរមកហើយពីមុនមានព្រះគម្ពីរសញ្ញាថ្មី ឬមានការនិយាយអំពីព្រះយេស៊ូវច្រើនឡើងៗ ហេតុដូច្នេះហើយ វាមិនអាចរក្សាថាព្រះគម្ពីរប៊ីប គឺជាអ្វីដែលធ្វើឱ្យមនុស្សម្នាក់ក្លាយជាគ្រីស្ទានទេ។ នៅក្នុងពាក្យសំដីនៃអ្នកប្រាជ្ញដែលគោរពព្រះគម្ពីរសញ្ញាថ្មី លោក អិន ធី រ៉ាយ និយាយថា: "ព្រះយេស៊ូវដែលមានព្រះជន្មឡើងវិញ នៅចុងបញ្ចប់នៃដំណឹងល្អរបស់ម៉ាថាយ មិនបាននិយាយ ថា: 'សិទ្ធិអំណាចទាំងអស់នៅស្ថានសួគ៌ និងលើផែនដីគឺត្រូវបានប្រទានឱ្យនៅក្នុងព្រះគម្ពីរដែលអ្នកទាំងអស់គ្នានឹងសរសេរនោះទេ' ផ្ទុយទៅវិញ 'សិទ្ធិអំណាចទាំងអស់នៅស្ថានសួគ៌ និងនៅលើផែនដីគឺត្រូវបានផ្តល់ឱ្យខ្ញុំ'"។ 10 ជាពាក្យម្យ៉ាងទៀតថា: "ព្រះគម្ពីរផ្ទាល់ចង្អុលបង្ហាញ...ចេញពីព្រះគម្ពីរ ហើយទៅកាន់ការពិតចុងក្រោយ សិទ្ធិអំណាចពិតប្រាកដដែលមាននៅនឹងព្រះផ្ទាល់"។ 11 ដូច្នេះព្រះគម្ពីរ គឺ *មិនមែន* ជាធនធានពិតចុងក្រោយ នៃចំណេះដឹងសំរាប់ពួកបរិសុទ្ធថ្ងៃចុង ក្រោយទេ។ ការណ៍ទាំងនេះគឺជាការបង្ហាញនូវប្រភពចុងក្រោយ។ ប្រភពចុងក្រោយនៃចំណេះដឹង និងសិទ្ធិអំណាចសំរាប់ពួកបរិសុទ្ធថ្ងៃចុងក្រោយគឺមានព្រះជន្មរស់នៅ។ ទំនាក់ទំនងនៃអំណោយទានទាំងនេះ មកពីព្រះជាវិវរណៈសកម្មអង់អាចដ៏ទេវភាព។12

គោលលទ្ធិនេះផ្តោតលើបេះដូង នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ហើយនិងសារលិខិតរបស់យើងដល់ពិភពលោក។ វាបង្កើតព្រឹត្តិការណ៍សំខាន់នៃជំនុំដ៏ឧឡារិកកាលពីថ្ងៃម្សិលមិញ ដែលយើងគាំទ្រលោក ថូម៉ាស អេស ម៉នសុន ជាព្យាការី ជាអ្នកមើលឆុត និងជាអ្នកទទួលវិវរណៈ។ យើងជឿលើព្រះ ដែលទ្រង់មានទំនាក់ទំនងនៅក្នុងជីវិតរបស់យើង ដែលទ្រង់មិនគង់ស្ងាត់ មិនអវត្តមាន ទាំងដូចជាអេលីយ៉ា បាននិយាយអំពីព្រះនៃសង្ឃរបស់ព្រះបាល តើលោក "[កំពុង] ធ្វើដំណើរ ឬប្រហែលជាដេកលក់ទេដឹង ហើយត្រូវតែ [ដាស់ទ្រង់ឡើង]" នោះទេ។ 13 នៅក្នុងសាសនាចក្រនេះ សូម្បីតែកុមាររបស់យើងសូត្រថា: "យើងខ្ញុំជឿចំពោះការណ៍ទាំងអស់ដែលទ្រង់បានបើកសម្តែងមក និងការណ៍ទាំងអស់ដែលទ្រង់បើកសម្តែងនៅពេលឥឡូវនេះ ហើយយើងខ្ញុំជឿថា ទ្រង់នឹងបើកសម្តែងនូវការណ៍ដ៏ធំ និងសំខាន់ៗជាច្រើនដែលទាក់ទងនឹងនគរនៃព្រះ"។14

នៅក្នុងការប្រកាសនូវព្រះគម្ពីរថ្មី និងវិវរណៈដែលកំពុងមានបន្ត យើងសូមអធិស្ឋានថាយើងនឹងមិនអួតអាង ឬគ្មានក្តីមេត្តាឡើយ។ ប៉ុន្តែបន្ទាប់ពីការនិមិត្តដ៏ពិសិដ្ឋនៅព្រៃពិសិដ្ឋបានឆ្លើយនូវសំណួរថា: "តើព្រះនៅមានព្រះជន្មដែរឬទេ?" អ្វីដែលយ៉ូសែប ស្ម៊ីធ និងសាសនាចក្រនៃ ព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ជំរុញឱ្យយើងប្រឈមមុខគឺជាសំណួរបន្ទាប់ដែលសំខាន់ដើម្បីធ្វើតាមថា: "តើទ្រង់ពិតជាមានព្រះបន្ទូលមែនទេ?" យើងនាំយកដំណឹងល្អថា ទ្រង់ពិតជាមានព្រះបន្ទូលក្នុងពេលឥឡូវនេះ ហើយទ្រង់បានមានព្រះបន្ទូលពីមុនជាមួយនឹងសេចក្តីស្រឡាញ់ និងកំណើតដ៏កក់ក្តៅ នៃពួកគ្រីស្ទានរបស់យើង យើងសូមអញ្ជើញមនុស្សទាំងអស់ឱ្យសួរនូវចម្ងល់នូវអ្វី ដែលព្រះបានមានព្រះបន្ទូលតាំងពីជំនាន់ព្រះគម្ពីរប៊ីប និងកំពុងមានព្រះបន្ទូលនៅពេលបច្ចុប្បន្ននេះ។

នៅក្នុងការយល់ដឹងរបស់លោកយ៉ូសែប និងអ្នកស្នងជាព្យាការីរបស់លោកនៅក្នុងសាសនាចក្របានឆ្លើយចំពោះសំណួរល្បងដែលលោក រ៉ាលហ្វ វ៉លដូ អែមើសុន បានផ្ដល់ឱ្យដល់សិស្សានុសិស្សនៃសាលាហាវើត ឌីវីនីធី កាលពី 170 ឆ្នាំកន្លងទៅ នៅរដូវក្ដៅដែលនឹងមកដល់នេះ។ ចំពោះក្រុមប្រូតេស្ដង់ដ៏ល្អ និងឧស្សាហ៍ព្យាយាម បុរសដែលពូកែខាងសំរុះសំរួលបានតវ៉ាឱ្យពួកគេបង្រៀនអំពី "ព្រះគឺជានរណា មិនមែនអំពីដែលបានមានព្រះបន្ទូល ឬមិនមានព្រះបន្ទូលនោះទេ"។15

ខ្ញុំសូមថ្លែងទីបន្ទាល់ថាស្ថានសួគ៌បើក។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា យ៉ូសែប ស្ម៊ីធ គឺ និងជាព្យាការីរបស់ព្រះ ថាព្រះគម្ពីរមរមនគឺ ពិតជា "សក្ខីយបទមួយទៀតអំពីព្រះយេស៊ូវគ្រីស្ទ"។ ខ្ញុំថ្លែងទីបន្ទាល់ថាលោក ថូម៉ាស អេស ម៉នសុន គឺជាព្យាការីរបស់ព្រះ ជាសាវកសម័យទំនើបដែលមានកូនសោនៃនគរនៅក្នុងដៃរបស់លោកជាបុរសដែលខ្ញុំបានឃើញដោយផ្ទាល់ នូវសិទ្ធិអំណាចដែលបានកើតមាន។ ខ្ញុំសូមថ្លែងទីបន្ទាល់នូវវត្តមាននៃសិទ្ធិអំណាចបែបនោះ សម្លេងនៃភាពជាព្យាការី និងវិវរណៈដែលកំពុងបន្ត បាននៅត្រង់បេះដូងនៃសារលិខិតរបស់ពួកគ្រីស្ទាន នៅពេលណាដែលការបំរើ នៃព្រះគ្រីស្ទបានអនុញ្ញាតឱ្យមាននៅលើផែនដី។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ការបំរើបែបនោះ *គឺ* មាននៅលើផែនដីម្ដងទៀត ហើយការបំរើនេះមាននៅក្នុងសាសនាចក្រ នៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ។ នៅក្នុងការលះបង់ដ៏ស្មោះសរបស់ពួកយើងចំពោះព្រះយេស៊ូវនៃណាសារ៉ែត ជាព្រះរាជបុត្រានៃព្រះ ជាព្រះអង្គសង្គ្រោះនៃពិភពលោក យើងសូមអញ្ជើញមនុស្សទាំងអស់ឱ្យសាកល្បង នូវអ្វីដែលយើងបានទទួលមកពីទ្រង់ ចូលរួមផឹកជាមួយយើងនូវ "រន្ធទឹកដែលផុសឡើងយ៉ាងផ្អែមល្ហែម ដល់ទៅបានជីវិតអស់កល្បជានិច្ច" 16 ការណ៍ទាំងនេះជាការរំលឹកខ្ជាប់ខ្ជួនថា ព្រះមានព្រះជន្មរស់ថាទ្រង់ស្រឡាញ់យើង ហើយថាទ្រង់មានព្រះបន្ទូល។ ខ្ញុំសូមបង្ហាញនូវអំណរគុណ *ផ្ទាល់ខ្លួន* យ៉ាងជ្រាលជ្រៅថា កិច្ចការរបស់ទ្រង់មិនដែលបញ្ចប់ទេ ហើយ "ព្រះបន្ទូលទ្រង់ពុំដែលឈប់ឈរឡើយ"។ ខ្ញុំសូមថ្លែងទីបន្ទាល់នូវចំណាប់អារម្មណ៍ជាទីស្រឡាញ់ដ៏ទេវភាព និងអ្វីៗដែលទាក់ទងនឹងការណ៍នេះ នៅក្នុងព្រះនាមដ៏ពិសិដ្ឋនៃព្រះយេស៊ូវគ្រីស្ទ អាម៉ែន។

កំណត់ចំណាំ

1. សូមមើល Stephen E. Robinson, Are Mormons Christians? (1991), 46។ The issue of canon is discussed on pages 45--56។
2. សូមមើល Bruce M. Metzger, *Manuscripts of the Greek Bible: An Introduction to Greek Paleography* (1981), 54--55។ *Are Mormons Christians?* 46។

3. ជាឧទាហរណ៍ សូមមើលចោទិយកថា 4:2 ។

4. ម៉ូសេ 1:4។

5. លី អិម ម៉ាកឌូណាល់ *The Formation of the Christian Biblical Canon* បោះពុម្ពឡើងវិញ (1995), 255--56។

6. សូមមើល "The Miracle of the Holy Bible" *Liahona* ខែ ឧសភា ឆ្នាំ 2007, 80—82។

7. យ៉ូសែប ស្ម៊ីធ---ប្រវត្តិ 1: 6, 12។

8. មរមន 7:9 ការសង្កត់ន័យជាការបន្ថែម។

9. គ. និង ស. 10:52 សូមមើលផងដែរ គ. និង ស. 20:11។

10. អិន ធី រាយធ៏ *The Last Word: Beyond the Bible Wars to a New Understanding of the Authority of Scripture* (2005), xi ។

11. រាយធ៏ *The Last Word*, 24 ។

12. ចំពោះការសរសេរនៃប្រធានបទនេះ សូមមើល ដាល្លិន អេក អូក "Scripture Reading and Revelation," *Ensign* ខែ មករា ឆ្នាំ 1995, 6--9 ។

13. ពង្សាវតារក្សត្រទី 1 18:27 ។

14. មាត្រានៃសេចក្ដីជំនឿ 1:9 ។

15. "An Address," *The Complete Writtings of Ralph Waldo Emerson* (1929), 45 ។

16. យ៉ូហាន 4:14 ។